ការិយាល័យកណ្ដាល

អេស៊ីលីដា
ACLEDA BANK

# សេចក្ដីជូនដំណឹង

## ស្ដីពី

## កិច្ចប្រជុំមហាសន្និបាតភាគហ៊ុនិកសាមញ្ញលើកទី២៣ របស់ធនាគារ អេស៊ីលីដា ភីអិលស៊ី

**ធនាគារ អេស៊ីលីដា ភីអិលស៊ី** (“ធនាគារ អេស៊ីលីដា”) មានកិត្តិយស សូមជម្រាបជូនដំណឹងដល់ភាគហ៊ុនិកទាំងអស់ ជ្រាបថា ដោយអនុលោមតាមសេចក្ដីសម្រេចរបស់ក្រុមប្រឹក្សាភិបាល **ចុះថ្ងៃទី២២ ខែមីនា ឆ្នាំ២០២៣** ធនាគារ អេស៊ីលីដា នឹងរៀបចំកិច្ចប្រជុំមហាសន្និបាតភាគហ៊ុនិកសាមញ្ញ (“កិច្ចប្រជុំ”) នៅការិយាល័យកណ្ដាល ធនាគារ អេស៊ីលីដា ដែលមានទីតាំងស្ថិតនៅ អគារលេខ ៦១ មហាវិថីព្រះមុនីវង្ស សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ នៅ**ថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២៣** វេលាម៉ោង**១៤:០០រសៀល**។

**របៀបវារៈនៃកិច្ចប្រជុំនេះ ត្រូវបានកំណត់ដូចខាងក្រោម៖**

| ល.រ | របៀបវារៈ | ម៉ោង |
|---|---|---|
| **១. ការចុះឈ្មោះរបស់ភាគហ៊ុនិក** | | ១២:០០ - ១៤:០០ |
| **២. បើកកិច្ចប្រជុំ** | | |
| ២.១. | មតិស្វាគមន៍របស់ប្រធានមហាសន្និបាត | ១៤:០០ - ១៤:០៥ |
| ២.២. | ការណែនាំសមាជិក-សមាជិកាក្រុមប្រឹក្សាភិបាល | ១៤:០៥ - ១៤:១០ |
| ២.៣. | អនុម័តរបៀបវារៈនៃកិច្ចប្រជុំ និងបទបង្ហាញអំពីដំណើរការនៃការបោះឆ្នោត | ១៤:១០ - ១៤:១៥ |
| **៣. សេចក្ដីសម្រេច** | | |
| ៣.១. | អនុម័តការបែងចែកភាគលាភ សម្រាប់ប្រាក់ចំណេញក្នុងឆ្នាំ២០២២ និងរក្សាប្រាក់ចំណេញដែលនៅសល់ក្នុងខ្ទង់ប្រាក់ចំណេញរក្សាទុក | ១៤:១៥ - ១៤:២៥ |
| ៣.២. | អនុម័តគោលការណ៍ភាគលាភ | ១៤:២៥ - ១៤:៣៥ |
| ៣.៣. | អនុម័តលើការតែងតាំងសមាជិកក្រុមប្រឹក្សាភិបាល សម្រាប់បន្តអាណត្តិ រយៈពេល៣ឆ្នាំបន្ថែមទៀត | ១៤:៣៥ - ១៤:៤៥ |
| ៣.៤. | អនុម័តលើការជ្រើសរើសសវនករឯករាជ្យប្រចាំ ធនាគារ អេស៊ីលីដា សម្រាប់ឆ្នាំហិរញ្ញវត្ថុ២០២៤ | ១៤:៤៥ - ១៥:០០ |
| ៣.៥. | អនុម័តការដំឡើងប្រាក់បៀវត្សប្រចាំឆ្នាំសម្រាប់ប្រធានក្រុមប្រឹក្សាភិបាល | ១៥:០០ - ១៥:១០ |
| ៣.៦. | អនុម័តកម្រៃសេវាសម្រាប់ក្រុមប្រឹក្សាភិបាល ៣% ស្របតាមអត្រាអតិផរណាឆ្នាំ២០២២ | ១៥:១០ - ១៥:២០ |
| ៣.៧. | អនុម័តកាលបរិច្ឆេទកំណត់ទុកសម្រាប់ភាគហ៊ុនិក ដែលត្រូវទទួលបានភាគលាភ | ១៥:២០ - ១៥:៣០ |
| ៣.៨. | អនុម័តការធ្វើវិសោធនកម្មលើមាត្រា៨ ឧបសម្ព័ន្ធ១ ឧបសម្ព័ន្ធ៣ និងឧបសម្ព័ន្ធ៤ នៃលក្ខន្តិកៈ ធនាគារ អេស៊ីលីដា | ១៥:៣០ - ១៥:៤០ |
| | សម្រាក (១៥នាទី) | |
| **៤. បញ្ហាដែលត្រូវពិភាក្សា និងរបាយការណ៍/បទបង្ហាញ** | | |
| ៤.១. | បទបង្ហាញ ស្ដីពីរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ របស់ធនាគារ អេស៊ីលីដា ដែលបានធ្វើសវនកម្មរួច សម្រាប់ដំណាច់ឆ្នាំ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ | ១៥:៥៥ - ១៦:០៥ |
| ៤.២. | របាយការណ៍របស់ប្រធានក្រុមប្រឹក្សាភិបាល សម្រាប់ឆ្នាំ២០២២ | ១៦:០៥ - ១៦:២០ |
| ៤.៣. | របាយការណ៍របស់ប្រធាននាយកប្រតិបត្តិ សម្រាប់ឆ្នាំ២០២២ | ១៦:២០ - ១៦:៤០ |

| ៥. បញ្ហាដែលត្រូវកំណត់ចំណាំ | | |
|---|---|---|
| ៥.១. | ផ្សេងៗ | ១៦:៤០ - ១៦:៥០ |
| ៥.២. | ប្រកាសលទ្ធផលនៃការបោះឆ្នោត | ១៦:៥០ - ១៧:០០ |
| **៦. មតិបិទកម្មវិធី** | | ១៧:០០ - ១៧:០៥ |

ភាគហ៊ុនិក ដែលមានឈ្មោះក្នុងបញ្ជីឈ្មោះភាគហ៊ុនិកនៅកាលបរិច្ឆេទកំណត់ទុក **ថ្ងៃទី២៧ ខែមីនា ឆ្នាំ២០២៣** នឹងទទួលបានលិខិតអញ្ជើញតាមរយៈមធ្យោបាយអេឡិចត្រូនិក ពីភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ របស់ធនាគារ អេស៊ីលីដា។ ក្រោយពីទទួលបានលិខិតអញ្ជើញ ភាគហ៊ុនិកទាំងអស់ ត្រូវបញ្ជាក់ពីការចូលរួមមហាសន្និបាតភាគហ៊ុនិក តាមរយៈមធ្យោបាយអេឡិចត្រូនិក ទៅកាន់ភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ របស់ធនាគារ អេស៊ីលីដា ឱ្យបានមុន**ថ្ងៃទី៤ ខែមេសា ឆ្នាំ២០២៣ វេលាម៉ោង១១:០០ព្រឹក**។

ភាគហ៊ុនិកអាចផ្តល់សិទ្ធិប្រទានទៅអ្នកតំណាងណាម្នាក់ឱ្យចូលរួមប្រជុំ និងបោះឆ្នោតជំនួស ក្នុងករណីដែលភាគហ៊ុនិកមិនអាចចូលរួមកិច្ចប្រជុំដោយខ្លួនឯងបាន។ លិខិតប្រគល់សិទ្ធិត្រូវបានផ្ញើជូនភាគហ៊ុនិកជាមួយគ្នានឹងសេចក្តីជូនដំណឹង ស្តីពីកិច្ចប្រជុំមហាសន្និបាតភាគហ៊ុនិក។ ភាគហ៊ុនិក ឬអ្នកតំណាងត្រូវផ្តល់លិខិតប្រគល់សិទ្ធិជូនធនាគារ អេស៊ីលីដា តាមរយៈមធ្យោបាយអេឡិចត្រូនិក ទៅកាន់ភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ របស់ធនាគារ អេស៊ីលីដា យ៉ាងយូរត្រឹម**ថ្ងៃទី៤ ខែមេសា ឆ្នាំ២០២៣ វេលាម៉ោង១១:០០ព្រឹក**។

***ភាគហ៊ុនិកនឹងត្រូវចាត់ទុកថា បានបោះបង់សិទ្ធិចូលរួមមហាសន្និបាតភាគហ៊ុនិក ប្រសិនបើមិនបានបញ្ជាក់ការចូលរួម ឬមិនផ្តល់លិខិតប្រគល់សិទ្ធិជូនភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ របស់ធនាគារ អេស៊ីលីដា តាមពេលកំណត់ខាងលើ។***

**បញ្ជាក់:** - ភាគហ៊ុនិក ឬអ្នកតំណាង (Proxy) ដែលអញ្ជើញចូលរួមកិច្ចប្រជុំមហាសន្និបាតភាគហ៊ុនិក សូមភ្ជាប់មកជាមួយនូវប័ណ្ណព័ត៌មានគណនីជួញដូរ និងអត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែន ដែលនៅមានសុពលភាព ដើម្បីផ្ទៀងផ្ទាត់ការចុះវត្តមានក្នុងកិច្ចប្រជុំមហាសន្និបាតភាគហ៊ុនិករបស់ធនាគារ។

សម្រាប់ព័ត៌មានបន្ថែម សូមទំនាក់ទំនងមកផ្នែកប្រតិបត្តិការបញ្ជិកាមូលបត្រ ភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ និងភ្នាក់ងារទូទាត់ (**ភ្នាក់ងារ RTP**) ដូចខាងក្រោម៖

- **លោក ហួត សុភី** ប្រធានផ្នែកប្រតិបត្តិការ RTP
  - ទូរស័ព្ទ: (៨៥៥) ១៥ ៩០០ ៥៣៨
  - អ៊ីម៉ែល: huot.sophy@acledabank.com.kh
- **លោក កែន រិទ្ធពុទ្ធា** អ្នកឯកទេសបឋមប្រតិបត្តិការ RTP
  - ទូរស័ព្ទ: (៨៥៥) ១៥ ៨០០ ៦៦៣
  - អ៊ីម៉ែល: ken.rithputhea@acledabank.com.kh
- **លោកស្រី សំរិទ្ធ វណ្ណីបុប្ផារដ្ឋ** បុគ្គលិកជាន់ខ្ពស់ផ្នែកប្រតិបត្តិការ RTP
  - ទូរស័ព្ទ: (៨៥៥) ៦១ ២៨៧ ៧៦៦
  - អ៊ីម៉ែល: op.rtp@acledabank.com.kh

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមភាគហ៊ុនិកទាំងអស់មេត្តាជ្រាបជាព័ត៌មាន។

ថ្ងៃពុធ ១កើត ខែចេត្រ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី២២ ខែមីនា ឆ្នាំ២០២៣

**ធនាគារ អេស៊ីលីដា ភីអិលស៊ី**